គម្រោងបន្ទាញបច្ចេកវិទ្យាដើម្បីបង្កើន
ផលិតភាព ជុំវិញតំបន់ទន្លេសាប
TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមបំប៉នមាន់សាច់



### ទីតាំងទំនាក់ទំនងទិញកូនមាន់ស្រុកចិញ្ចឹម

ខេត្ត កំពង់ចាម

- ក្រុងសួង: ចេវ ស្រីម៉ៅ 097 613 0297
- ស្រុកជើងព្រៃ: ហួរ ប៊ុនថេង 089 468 277
- ស្រុកកំពង់សៀម: ហុក ឡុងស្រេង 012 783 104

ខេត្ត បន្ទាយមានជ័យ

- ស្រុកមង្គលបុរី: ផាន ភាព 092 933 883
- ស្រុកអូរជ្រៅ: ហេង គឹមហ៊ិន 088 444 7994
- ស្រុកព្រះនេត្រព្រះ: ភ្លឹង សុណ្ណដា 092 829 021

ខេត្ត សៀមរាប

- ស្រុកសូទ្រនិគម: លី ស៊ីណាត 012 483 440

ឧបត្ថម្ភថវិកាដោយ:
រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

ខែ មេសា ឆ្នាំ ២០១៣

## សេចក្តីផ្តើម

ការចិញ្ចឹមមាន់ស្រុក ផ្តល់ប្រភពចំណូលបន្ថែមជាប្រចាំដល់គ្រួសារ ដោយចំណាយពេលទំនេរ និង ធនធានមួយចំនួនប៉ុណ្ណោះ។ កូនមាន់ស្រុកនៅកន្លែងភ្ញាស់នេះ ទទួលបានការគ្រប់គ្រងតាមបច្ចេកទេសត្រឹមត្រូវ ជួយមិនឲ្យមាន់ឈឺ និងងាប់ដោយសារជម្ងឺកាចសាហាវនានា។ ពូជមាន់ក្នុងស្រុកមានការពេញនិយមពីអ្នកហូប មានតម្រូវការទីផ្សារខ្ពស់ និងងាយស្រួលលក់ (មានតម្លៃថ្លៃ) ។ តាមរយៈបច្ចេកទេសចិញ្ចឹមនេះ កូនមាន់ស្រុក ១ក្បាល (អាយុ ២១ ថ្ងៃ) ចិញ្ចឹមក្នុងរយៈពេលតែ ៨៥ថ្ងៃ អាចទទួលបានទម្ងន់ជាមធ្យម ១,២គីឡូក្រាម។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមអាចទទួលបានប្រាក់ចំណេញសុទ្ធ ក្នុង ១គីឡូក្រាមមាន់រស់ ជាមធ្យមពី ៦០០០ ទៅ ៧០០០រៀល ។ ប្រាក់ចំណូលសរុប នឹងកើនឡើង បើកសិករចិញ្ចឹមកូនមាន់ស្រុកបំប៉នយកសាច់កាន់តែច្រើន។

## គុណសម្បត្តិកូនមាន់ស្រុកភ្ញាស់នៅកសិដ្ឋានសម្រាប់យកទៅចិញ្ចឹមបំប៉ន

- កូនមាន់មានសុខភាពល្អ និងលូតលាស់លឿន
- មានអាយុពី ២១ ដល់ ៣០ថ្ងៃ និង មានទម្ងន់សមស្របសម្រាប់ចិញ្ចឹម
- ចិញ្ចឹមមិនងាយឈឺ ដោយបានចាក់វ៉ាក់សាំងការពារជម្ងឺ ២-៣មុខ រួចជាស្រេច (ជម្ងឺញ៉ូវកាស កំប៉ូរ៉ូ និង អុត) ។ អ្នកចិញ្ចឹមសាច់ត្រូវចាក់បន្ថែម វ៉ាក់សាំងជម្ងឺអាសន្នរោគ នៅពេលមាន់អាយុបាន ២ខែ។

## តើចិញ្ចឹមមាន់សាច់ដូចម្តេច ឲ្យទទួលបានជោគជ័យ ?

### ១. ការសង់ទ្រុងគំរូចិញ្ចឹមបំប៉នកូនមាន់សាច់

- ទ្រុងបណ្តោយ ៦ម និងទទឹង ៣ម ចែកជា ២បន្ទប់
- ជើងរៀងទ្រុងមានកំពស់ ១,៧ម និងសសរកណ្តាលកំពស់ ៣,២ម
- បាំងសំណាញ់ចេញក្រៅពី ៣ទៅ ៤ម និងចែកជាបន្ទប់ៗ សម្រាប់មាន់ដើរខាងក្រៅ និងហាលថ្ងៃ




- ធ្វើធ្នើរមាន់ដេក កំពស់ពីដី ០,៧ម និងបន្ទាធ្នើរ ០,៧ម
- ផ្ទៃដី ១ម$^{២}$ (កន្លែងដេក) ដាក់មាន់បានពី ៧ ទៅ ៨ក្បាល



### ២. ស្នូកចំណី និងស្នូកទឹកមាន់

ស្នូកចំណី អាចច្នៃពីប៊ីដុង ឬកានជ័រតូចធំ។





## ៣. របៀបជ្រើសរើសកូនមាន់ចិញ្ចឹម



- រាងល្អ ក្លៀវក្លា ដើរលឿន
- មានអាយុយ៉ាងតិច ២១ថ្ងៃ
- មិនត្រូវចិញ្ចឹមកូនមាន់មានរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ ឬរឹង និងមានពណ៌ខៀវ
- កូនមាន់ចាក់វ៉ាក់សាំងការពារជម្ងឺធ្លងបានយ៉ាងតិច ៣មុខ (ជម្ងឺញ៉ូវកាស កំបូរ៉ូ និងអុតមាន់)

**ប្រយ័ត្ន:** មិនត្រូវទិញកូនមាន់មិនស្គាល់ប្រភពមកចិញ្ចឹម

## ៤. តើគួររៀបចំទ្រុងមុនដាក់កូនមាន់ចិញ្ចឹមដូចម្ដេច?

- ផ្ទៃបាតទ្រុងត្រូវស្ងួតជានិច្ច
- បាចកំបោរក្នុងទ្រុង ឬបាញ់ទឹក ធីអេចហ្វ័រ (TH4) រៀងរាល់មុនដាក់មាន់ចិញ្ចឹម ១អាទិត្យ
- ក្រាលអង្កាមបាតទ្រុងកំរាស់ ១ ទៅ ២សង់ទីម៉ែត្រ





## ៥. ការថែរក្សាកូនមាន់ក្រោយដឹកជញ្ជូនឆ្ងាយ



បើកូនមាន់ដឹកជញ្ជូនរយៈពេលយូរ ឬ ផ្លូវឆ្ងាយត្រូវឲ្យកូនមាន់ផឹកទឹកលាយទឹកក្រូចឆ្មា ឬថ្នាំវីតាមីនសេ មានរសជាតិជូរតិចៗក្រោយពីដល់កន្លែងចិញ្ចឹមបានបន្តិច

## ៦. ចំណីអាហារសម្រាប់មាន់

### តើត្រូវផ្សំចំណីដូចម្ដេច ដើម្បីឲ្យមាន់ធំធាត់លឿន និងចំណាយថវិកាតិច?

- លាយចំណីផ្សំស្រេច (បារ) ៥០% និងចំណីរកក្នុងភូមិ ៥០% ដូចជា៖ ស្រូវ ចុងអង្ករ កន្ទក់ ពោត (បុក ឬ កិន) ត្រកួន ស្លោ ផ្ទី ស្លឹកបាស កន្ទំថេត ចកបាយទា ។ល។
- បន្ថែមម្សៅខ្ចង ខ្ចៅ លៀស ឬ សំបកក្ដាម លាយក្នុងចំណី ចំនួន ១ស្លាបព្រាកាហ្វេ រៀងរាល់ពី ២ ទៅ ៣ថ្ងៃម្ដង។






## ៧. អនាម័យការចិញ្ចឹមមាន់



- មុនដាក់មាន់ចិញ្ចឹម ១អាទិត្យ ត្រូវសំអាតទ្រុង និងបាចទឹកកំបោរថ្មសម្លាប់មេរោគ
- ដាក់ចិញ្ចឹមជាក្រុមតាមអាយុ
- ដាក់ម្សៅកំបោរថ្មនៅមាត់ទ្វារចូលដើម្បីសំលាប់មេរោគនៅបាតស្បែកជើងមុនចូលទ្រុង
- ផ្លាស់ប្ដូរទឹកស្អាតផឹក ឲ្យបានញឹកញាប់
- ត្រូវបញ្ចេញមាន់លក់ទាំងអស់ក្នុងទ្រុងជាមួយគ្នា

☠ <u>ការប្រុងប្រយ័ត្ន</u>

- ចំពោះមាន់ងាប់ដោយជម្ងឺ ត្រូវដុត ឬ កប់ចោល។
- ហាមដាច់ខាត មិនឲ្យឈ្មួញទិញមាន់ និងអ្នកដទៃចូលក្នុងទ្រុងមាន់ ឬ ក្នុងទីធ្លាចិញ្ចឹមមាន់។

## ៨. វិធានការការពារជម្ងឺឆ្លង និងទម្លាក់ព្រូនមាន់

ជម្ងឺមាន់កាចសាហាវ រាលដាលខ្លាំង និងបណ្ដាលឲ្យមាន់ងាប់ច្រើន។ ដូច្នេះ ដើម្បីកុំឲ្យមាន់កើតជម្ងឺ ចាំបាច់ត្រូវ៖

- ចាក់វ៉ាក់សាំងការពារមុនពេលសត្វឈឺ
- ត្រូវចាក់វ៉ាក់សាំងការពារដល់មាន់ទាំងអស់ និងទៀងទាត់
- មាន់ ១ក្បាល ត្រូវផ្ដល់វ៉ាក់សាំងការពារយ៉ាងតិចបំផុតឲ្យបាន ៤មុខ (ជម្ងឺញ៉ូវកាស កំបូរ៉ូ អុតមាន់ និងអាសន្នរោគ)
- ត្រូវផ្ដល់ថ្នាំទម្លាក់ព្រូនរៀងរាល់ ៣ខែម្ដង

### កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺឆ្លង និងទម្លាក់ព្រូន




រៀបចំដោយ: លោក ស៊ិន ប៉ោ
អ្នកជំនាញផ្នែកបសុសត្វ (TSTD)
porsinn@gmail.com

<u>ព័ត៌មានបច្ចេកទេសផ្សេងទៀត</u>: www.telecentercambodia.org/